# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤២២ ព្រទ/២០០១

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**ឯកឧត្តមប្រធានតុលាការកំពូល**

**លោកជំទាវប្រធានសាលាឧទ្ធរណ៍**

**លោកប្រធានតុលាការខេត្ត-ក្រុង**

**<u>កម្មវត្ថុ</u>:** សំណើចាត់បញ្ជូនសេចក្តីចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ មកទីស្តីការក្រសួងយុត្តិធម៌សម្រាប់ការងារបញ្ជីថ្កោលទោស ។

ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ អស់លោកជាប្រធានតុលាការគ្រប់ជាន់ថ្នាក់ជ្រាបថា ក្រសួងយុត្តិធម៌មានភារកិច្ចគ្រប់គ្រង និងប្រមូលសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ របស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងព្រះរាជក្រឹត្យ ព្រមទាំងសេចក្តីសម្រេចនានា ស្តីពីការបន្ធូរបន្ថយទោស លើកលែងទោសនឹងការលុបលាងទោសដើម្បីតម្កល់ទុកជាឯកសារសម្រាប់រៀបចំបញ្ជី និងគ្រប់គ្រងបញ្ជីថ្កោលទោស ។

កន្លងមក តុលាការគ្រប់ជាន់ថ្នាក់មួយចំនួនបានយកចិត្តទុកដាក់ចាត់បញ្ជូនសេចក្តីចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាព មកទីស្តីការក្រសួងយុត្តិធម៌ បានទាន់ពេលវេលា និងទៀងទាត់ជារៀងរាល់ខែរៀងរាល់ឆ្នាំតាមការកំណត់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ទន្ទឹមនឹងនេះដែរ ក៏នៅមានតុលាការមួយចំនួននៅមិនទាន់ចាត់បញ្ជូនសេចក្តីចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ មកទីស្តីការក្រសួងយុត្តិធម៌ឱ្យបានទាន់ពេលវេលាកំណត់ ដែលជាហេតុនាំឱ្យក្រសួងមានការលំបាកក្នុងការគ្រប់គ្រង ការចាត់ចែងផ្តល់លិខិតថ្កោលទោសជូនសាធារណជន។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តម លោកជំទាវ អស់លោកជាប្រធានតុលាការគ្រប់ជាន់ថ្នាក់ជួយរៀបចំចាត់ចែងសេចក្តីចម្លងសាលក្រម សាលដីកាស្ថាពរ មកក្រសួងឱ្យបានត្រឹមត្រូវទាន់ពេលវេលា ប្រយោជន៍ធានាបាននូវប្រសិទ្ធិភាពក្នុងការគ្រប់គ្រង សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។

សូមឯកឧត្តម លោកជំទាវ អស់លោកប្រធានតុលាការខេត្ត-ក្រុង ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**នាង ស៊ីផុន**